ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ
លេខ:៥៥៦/២៧-០៧-២០១០
សាលដីកា
លេខ:២០ ក្រ$_{IV}$ត/០៥-០៣-២០១៤

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៥ ខែ មិនា ឆ្នាំ ២០១៤ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ៥៥៦ចុះថ្ងៃទី២៧-០៧-២០១០ រវាង៖

១-ជនជាប់ចោទឈ្មោះ [redacted] សំអៀន ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរលក់សាច់ក្រក់ ទីកន្លែងកំណើតភូមិមេរងថ្មី ឃុំថ្នូរដៃ ស្រុកថ្នូរដៃ ខេត្តព្រះត្រពាំង ប្រទេសវៀតណាម ទីលំនៅបច្ចុប្បន្នភូមិ២ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ ថាច់ យន(រ) មានកូន០២នាក់ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ២ឆ្នាំ ពីបទ បង្ករបួសស្នាម ។

ត្រូវចោទពីបទៈប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅសង្កាត់៤ ក្រុង ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៩-០៨-២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ពងទាកូន ទីលំនៅសព្វថ្ងៃភូមិ២ [redacted] ។

**៦រឿងហេតុមានដូចតទៅៈ**

តាមរបាយការណ៍របស់សមត្ថកិច្ចបញ្ជាក់ថា កាលពីថ្ងៃទី០៩-០៨-២០០៩ វេលាម៉ោង៩ និង១០នាទី ជនជាប់ចោទឈ្មោះ [redacted] សំអៀន បានធ្វើសកម្មភាពស្ទាបអង្អែលខ្លួនប្រាណ និង

៩៧





Scanned with CamScanner

ស្រាតខោអាវជនរងគ្រោះឈ្មោះ [redacted] ធីបែរហោយ ជាកូនបង្កើតបំរុងរំលោភ តែត្រូវជនរងគ្រោះធាក់ចេញហើយរើបំរះគេចខ្លួនតែម្តង ។ ក្រោយមកឈ្មោះ [redacted] ហេង ដែលជាម្តាយបង្កើតរបស់ជនរងគ្រោះបានទៅប្តឹងសមត្ថកិច្ចប៉ូលីសមកជួយធ្វើអន្តរាគមន៍ បន្ទាប់មកសមត្ថកិច្ចបានចុះស្រាវជ្រាវដល់កន្លែងកើតហេតុ ព្រមទាំងបានពិនិត្យភស្តុតាងនានា សួរចម្លើយជនរងគ្រោះឈ្មោះ [redacted] ធីបែរហោយ និងជនជាប់ចោទឈ្មោះ [redacted] សំអឿន រួចចាប់ឃាត់ខ្លួនឈ្មោះនេះមកសាលាដំបូងខេត្តព្រះសីហនុចាត់ការតាមច្បាប់ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៣៨ (គ) ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារសេចក្តីសម្រេចដូចតទៅៈ

១-ផ្តន្ទាទោសឈ្មោះ [redacted] សំអឿន (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល១០ឆ្នាំ(ដប់ឆ្នាំ) គិតពីថ្ងៃទី១១-០៨-២០០៩ ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិ២ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៥ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

២-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨-០៦-២០១០ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ កំបាំងមុខជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ។ បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨-០៦-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] សំអឿន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៣៨(គ) ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តព្រះសីហនុ គ្រង់ចំណុចសេចក្តីសម្រេចនៃសាលក្រមទាំងមូល ។

## <u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] សំអឿន បានឆ្លើយបញ្ជាក់ថា ក្មេងស្រីជាកូនបង្កើតខ្លួនជាមួយប្រពន្ធមុនដែលបានបែកគ្នា ក្រោយមកម៉ែវាបានមកយកកូនទៅនៅហាងភ្នំខៀវ ហើយកូននោះអាយុ១៩ឆ្នាំ ។ ផ្ទះខ្លួនរស់នៅមានគ្នា៥នាក់ ប្រពន្ធក្រោយមានកូន០២នាក់ ហើយកូនដើមដេកលើគ្រែជាមួយប្អូនអាយុ១៣ឆ្នាំ ឯខ្លួនដេកលើឥដ្ឋជាមួយប្រពន្ធនិងកូនម្នាក់ទៀត ។ ខ្លួនមិនបានប៉ះពាល់លើកូនទេ ហើយនៅថ្ងៃទី០៨-៩-២០០៩ ខ្លួនបានទៅតាមរកកូននៅហាងភ្នំខៀវក៏ត្រូវគេឃាត់ខ្លួន។ សំណូមពរសុំបន្ធូរបន្ថយទោស ព្រោះខ្លួនត្រូវរកចិញ្ចឹមគ្រួសារ ។

តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ធីបែរហោយ ឆ្លើយថាៈ ខ្លួនមកស្រុកខ្មែរថ្ងៃទី០៦-៦-២០០៩ មកស្នាក់នៅជាមួយឪពុកបង្កើតឈ្មោះ [redacted] សំអឿន ។ នៅក្នុងខែកក្កដា ឆ្នាំ២០០៩ ឪពុកខ្លួនបានច្របាច់ដៃជើងខ្លួន ពេលខ្លួនកំពុងដេកម៉ោងប្រហែល២១-២២យប់ ហើយបានសើយអាវខ្លួនឡើង ដោះខោ ថើបអង្អែលខ្លួនប្រាណ ។

-តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋានៈ

តាមអង្គហេតុរឿងនេះខ្ញុំយល់ឃើញថា ពុំមានភស្តុតាងពីបទរំលោភទេ អំពើនេះកើតពីបណ្តឹងរបស់ដើមបណ្តឹងនិងចម្លើយជនរងគ្រោះ ហើយក៏ត្រូវតុលាការដាក់ទណ្ឌកម្ម ។ តាមចំណាររបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បញ្ជាក់ថា មិនមែនបទរំលោភសេពសន្ថវៈទេ គឺបទប្រទូស្តកេរខ្មាស់ យោងតាមមាត្រា២៧,២៨៦ សុំក្រុមប្រឹក្សាសំរេចតាមច្បាប់ ។

-មេធាវីតំណាងឲ្យជនជាប់ចោទផ្តល់សេចក្តីសន្និដ្ឋានៈ



Scanned with CamScanner

ឆ្លងតាមការសួរដេញដោល ឯកសារពាក់ព័ន្ធ និង ចម្លើយបដិសេធការចោទប្រកាន់របស់ជនជាប់ចោទ ឃើញថា រឿងហេតុកើតឡើងដោយសារប្រពន្ធដើមកូនក្តីខ្លួនចង់បានកូនទៅធ្វើការនៅភោជនីយដ្ឋាន ហើយកូនក្តីខ្លួនតាមយកកូនមកវិញ ។ អង្គហេតុមានដូចតំណាងមហាអយ្យការបញ្ជាក់ ស្ថានភាពនៃកន្លែងកើតហេតុមិនអាចរំលោភកើតទេ ព្រោះទីនោះមានគ្នា៥នាក់ មានគ្រែតែមួយ ជាការមូលបង្កាច់ទេ ហើយមិនមានភស្តុតាងគ្រប់គ្រាន់ថា មានអំពើនោះកើតឡើងដែរ ។ សុំក្រុមប្រឹក្សាមេត្តាផ្តល់ភាពយុត្តិធម៌ដល់កូនក្តីខ្លួនផង ហើយបើយោងតាមមាត្រា២៦៤ កូនក្តីខ្លួនបានជាប់ឃុំជាង៥ឆ្នាំហើយ ។

-ក្រោយពីបានស្តាប់ការអានចម្លើយដើមបណ្តឹង ជនរងគ្រោះ និង សាក្សី

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ

## **យល់ឃើញថា**

១-បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨-០៦-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] សំអឿន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៣៨(គ) ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២-ជនជាប់ចោទបានបដិសេធការចោទប្រកាន់នាពេលសវនាការ ដោយអះអាងថា ក្មេងស្រីជាកូនបង្កើតខ្លួនជាមួយប្រពន្ធមុនដែលបានលែងលះគ្នា ហើយវានៅជាមួយខ្លួន តែម៉ែវាបានមកយកកូនទៅនៅហាងភ្នំឌៀរ៣ដង ដល់នៅថ្ងៃទី០៨-៩-២០០៩ ខ្លួនបានទៅតាមរកកូនក៏ត្រូវគេឃាត់ខ្លួន ។ ប៉ុន្តែតាមចម្លើយជនរងគ្រោះថា ខ្លួនមកស្រុកខ្មែរថ្ងៃទី០៦-៦-២០០៩ ស្នាក់នៅជាមួយឪពុកបង្កើតឈ្មោះ [redacted] សំអឿន ។ នៅក្នុងខែកក្កដា ឆ្នាំ២០០៩ ឪពុកខ្លួនបានច្របាច់ដៃជើងខ្លួនពេលកំពុងដេកម៉ោងប្រហែល២១-២២យប់ ហើយបានសើយអាវខ្លួនឡើងថើប អង្អែលខ្លួនប្រាណ ត្រូវខ្លួនរើបំរះទះគាត់មួយដៃ បន្ទាប់មកខ្លួនបានធាក់មួយជើង ។ សកម្មភាពរបស់ជនជាប់ចោទមិនចូលក្នុងបទប៉ុនប៉ងរំលោភសេពសន្ថវៈទេ គប្បីតុលាការធ្វើការកែប្រែ បទចោទមកជា បទប្រទូស្តកេរខ្មាស យោងតាមមាត្រា២៤៦នៃក្រមព្រហ្មទណ្ឌ។

៣-សាលក្រមព្រហ្មទណ្ឌលេខ៣៨ (គ) ចុះថ្ងៃទី០៨-០៦-២០១០ របស់សាលាដំបូងខេត្តព្រះសីហនុ បានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមខាងលើទុកជាបានការ លើកលែងតែចំណុចទី១ គប្បីកែតម្រូវឡើងវិញតាមការយល់ឃើញខាងលើ។

## **វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨-០៦-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] សំអឿន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-កែប្រែបទចោទប្រកាន់ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈតាមមាត្រា៥ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ទៅជាបទប្រទូស្តកេរខ្មាស តាមមាត្រា២៤៦នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៣៨ (គ) ចុះថ្ងៃទី០៨-០៦-២០១០ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការ លើកលែងតែចំណុចទី១ នៃសាលក្រមត្រង់ "ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សំអៀន ដាក់ពន្ធនាគារ១០ឆ្នាំ (ដប់ឆ្នាំ) ត្រូវកែប្រែជា "ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សំអៀន ដាក់ពន្ធនាគារ ៣ឆ្នាំ(បីឆ្នាំ) ពីបទ ប្រទូស្តកេរខ្មាស តាមមាត្រា២៤៦នៃក្រមព្រហ្មទណ្ឌ។ ចំណុចដទៃទៀតនៅរក្សាទុកជាបានការ ។

៤-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

សាលដីកានេះជំនុំជំរះចំពោះមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទឈ្មោះ ថាច់ សំអៀន ប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤ បើកសិទ្ធិប្តឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកានិងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះអោយបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner